# ឧបសម្ព័ន្ធ

នៃប្រកាសលេខៈ៧៣៥សហវ.គរ ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៨ របស់
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពី ការគ្រប់គ្រងទំនិញកំណត់ពិសេស

**១. បញ្ជីមុខទំនិញកំណត់ពិសេស** : មុខទំនិញកំណត់ពិសេសរួមមាន ៖

- មុខទំនិញជាប់ពន្ធខ្ពស់តាមបញ្ញត្តិប្រការ ២ នៃប្រកាសស្តីពីការគ្រប់គ្រងទំនិញកំណត់ពិសេស

- មុខទំនិញស្ថិតនៅក្នុងបញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់ក្នុងការនាំចេញ ឬនាំចូល ស្របតាមបញ្ញត្តិនៃអនុក្រឹត្យស្តីពីការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់

- មុខទំនិញផ្សេងៗទៀតដូចមានចែងខាងក្រោម :

១. បន្លែ ផ្លែឈើ មើមឈើ ត្រី សាច់ គ្រប់ប្រភេទ
២. ម្សៅមី
៣. ប្រេងឆា
៤. គ្រឿងឧបភោគ បរិភោគ
៥. សុរា និងស្រាបៀរ
៦. ទឹកដោះគោក្នុងទម្រង់រាវ ខាប់ ឬម្សៅ ទោះមានជាតិស្ករក្តី
៧. ភេសជ្ជៈគ្រប់ប្រភេទទោះគ្មានជាតិស្ករ ឬគ្មានជាតិអាល់កុលក្តី
៨. បារីគ្រប់ប្រភេទ
៩. ផលិតផលតេលសិលា
១០. ប៊ីចេង
១១. ប្រេងខ្យល់ និងប្រេងកូឡា
១២. ផលិតផលគ្រឿងសម្អាង
១៣. សាប៊ូ ឬផលិតផលសម្រាប់លាងសម្អាត និងថែរក្សាអនាម័យ
១៤. សំបកកង់យានយន្ត និងគ្រឿងចក្រ
១៥. ក្រដាសគ្រប់ប្រភេទ
១៦. ក្រណាត់ សម្លៀកបំពាក់ រួមទាំងគ្រឿងផ្សំ ឬបំណែក
១៧. ម៉ាស៊ីន ឬបរិធានមេកានិកអគ្គិសនី ឬអេឡិចត្រូនិច រួមទាំងគ្រឿងបន្លាស់ និងបំណែក
១៨. ម៉ាស៊ីនភ្លើង អាគុយ ថ្មពិល
១៩. ឧបករណ៍ និងបរិក្ខារទូរគមនាគមន៍ រួមទាំងគ្រឿងបន្សំ
២០. យានយន្ត និងគ្រឿងចក្រ រួមទាំងគ្រឿងបន្លាស់ និងបំណែក
២១. ឧបករណ៍ និងសម្ភារៈល្បែងគ្រប់ប្រភេទ

**២. កំណត់សម្គាល់**

- ការបិទត្រាពន្ធគយលើមុខទំនិញនីមួយៗ ត្រូវអនុវត្តតាមបញ្ញត្តិនៃសេចក្តីជូនដំណឹងលេខ ០៦២ សហវ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការបិទត្រាពន្ធគយ លើទំនិញមួយចំនួនដែលនាំចូលក្រោមរបបនាំចូលស្ថាពរ ដោយបង់ពន្ធ និងអាករតាមច្បាប់ជាធរមាន និងតាមសេចក្តីណែនាំផ្លូវការពីពេលមួយទៅពេលមួយរបស់នាយកទីចាត់ការគយ និងរដ្ឋាករ ។

- ការបិទលតាប័ត្រលើយានយន្ត ឬគ្រឿងចក្រគ្រប់ប្រភេទត្រូវអនុលោមតាមបញ្ញត្តិជាធរមាននានាពាក់ព័ន្ធនឹងការគ្រប់គ្រងលតាប័ត្រយានយន្ត ។